00198229

C22/I/49

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

អង្គបុរេជំនុំជម្រះ

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ០២ កក្កដា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02/July/2008
ម៉ោង (Time/Heure): 13:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

---

## សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលបានសម្រេចផ្ទាល់មាត់នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៨ អំពីសំណើសុំពន្យារពេលសវនាការលើបញ្ហាយុត្តាធិការរបស់សហមេធាវីការពារក្តី

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07/JULY/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

**ជនត្រូវចោទ**
អៀង សារី

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G.KARNAVAS

00198230



C22/I/49

១- នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចាប់ផ្តើមបើកសវនាការលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត។

២- សហមេធាវីការពារក្តីបានលើកជាបញ្ហាបឋមថា ដោយសារជនត្រូវចោទមិនទាន់បានអ្នកជំនាញផ្នែកចិត្តសាស្ត្រពិនិត្យសុខភាពក្នុងការចូលរួមក្នុងសវនាការបាននៅឡើយ ដូច្នេះនីតិវិធីទាក់ទងនឹងបញ្ហាយុត្តាធិការដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍គួរតែពន្យារពេល។

៣- សហមេធាវីការពារក្តីបានលើកឡើងថា នេះគឺជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទដើម្បីចូលរួម និងជួយរៀបចំការពារខ្លួន។ សហមេធាវីការពារក្តីបានអះអាងថាជនត្រូវចោទអាចមិនមានសមត្ថភាពធ្វើដូច្នេះបានទេ ដោយសារតែជនត្រូវចោទពុំមានសមត្ថភាពខាងស្មារតីគ្រប់គ្រាន់។ ចំពោះបញ្ហានេះ សហមេធាវីការពារក្តីបានលើកឡើងថា ផ្អែកតាមការធ្វើទំនាក់ទំនងរបស់ខ្លួនជាមួយជនត្រូវចោទ និងការពិតដែលថា ជនត្រូវចោទហាក់ដូចជាមិនយល់បានពេញលេញពីបញ្ហាយុត្តាធិការ សហមេធាវីការពារក្តីមិនច្បាស់ថាតើជនត្រូវចោទអាចចូលរួម និងជួយរៀបចំការពារខ្លួនបានដែរឬយ៉ាងណានោះទេ។

៤- នៅដំណាក់កាលដំបូងនៃនីតិវិធី សហមេធាវីការពារក្តីបានបញ្ជាក់ថា ខ្លួនបានដាក់សំណើសុំចាត់តាំងអ្នកជំនាញទៅសហចៅក្រមស៊ើបអង្កេតដើម្បីឲ្យពិនិត្យសុខភាពរបស់ជនត្រូវចោទក្នុងការចូលរួមក្នុងសវនាការ។ ប៉ុន្តែតាមការអះអាងរបស់សហមេធាវីការពារក្តី សំណើនេះពុំទាន់បានសម្រេចនៅឡើយ។ តាមសហមេធាវីការ-ពារក្តី សហចៅក្រមស៊ើបអង្កេតបានជម្រាបជូនខ្លួនថា នឹងមានសេចក្តីសម្រេចមុនដីកាដំណោះស្រាយ។ សហមេធាវីការពារក្តីបានលើកឡើងថា ខ្លួនបានព្យាយាមប្តឹងឧទ្ធរណ៍ចំពោះការមិនបានសម្រេចលើសំណើនេះ ប៉ុន្តែ ការព្យាយាមប្តឹងនេះត្រូវបានសហចៅក្រមស៊ើបអង្កេតមិនទទួលយក។

៥- អង្គបុរេជំនុំជម្រះ កត់សំគាល់ឃើញថា ពុំមានការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចណាមួយរបស់សហចៅក្រមស៊ើបអង្កេតនៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះពិចារណាយល់ឃើញថាករណីនេះអាចប្តឹងឧទ្ធរណ៍ចំពោះការខកខានរបស់សហចៅក្រមស៊ើបអង្កេតអោយសម្រេចលើសំណើនេះបាន ដោយសារទង្វើរបស់សហចៅក្រមស៊ើបអង្កេតអាចត្រូវបានបកស្រាយថាជាការបដិសេធពាក្យបណ្តឹងតាមការសន្មត។ ។

៦- ទាក់ទងនឹងបញ្ហានេះ នៅពេលនេះ អង្គបុរេជំនុំជម្រះពុំអាចវិនិច្ឆ័យលើទង្វើរបស់សហចៅក្រមស៊ើបអង្កេតដូចដែលបានអះអាងនោះឡើយ។ ដូច្នេះ បញ្ហានៅចំពោះមុខយើង គឺវាមានកម្រិតចំពោះការអះអាងរបស់សហមេធាវីការពារក្តីរបស់ជនត្រូវចោទដែលថាជនត្រូវចោទមិនអាចចូលរួម ឬជួយរៀបចំការពារខ្លួនលើបញ្ហាយុត្តា

ធិការដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខអង្គបុរេជំនុំជម្រះ។

៧- អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថែមទៀតថា សហមេធាវីការពារក្តីពុំបានលើកឡើងពីអង្គហេតុ ឬខបទ្ទុរហេតុណាមួយដែលយកជាមូលដ្ឋានក្នុងការសន្និដ្ឋានដូចដែលបានលើកឡើងខាងលើនោះឡើយ។ អង្គហេតុតែមួយគត់ដែលថា សហមេធាវីការពារក្តីបានកត់សំគាល់ឃើញថា ជនត្រូវចោទពុំអាចយល់បានពេញលេញលើស្មុគស្មាញនៃបញ្ហាយុត្តាធិការ គឺវាមិនមានលក្ខណៈគ្រប់គ្រាន់ដែលនាំអោយសន្និដ្ឋាននៅដំណាក់កាលនេះបានថា អង្គបុរេជំនុំជម្រះគួរចាត់តាំងអ្នកជំនាញអោយពិនិត្យសមត្ថភាពស្មារតី ដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធីនេះនោះឡើយ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេច:**

*បដិសេធសំណើសុំពន្យារពេលសវនាការ។*

**សេចក្តីសម្រេចផ្ទាល់មាត់ធ្វើឡើងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨** ៧

ភ្នំពេញ, ថ្ងៃទី០២ ខែ កក្កដា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C.

**ប្រាក់ គីមសាន**